ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះតុលាការកំពូលសម្រេចចាត់ចំណាត់ប្រភេទឡើងវិញ នូវឯកសារសម្ងាត់ចំនួន ១.៧០០ ច្បាប់

អង្គជំនុំជម្រះតុលាការកំពូលបានបញ្ចប់ការពិនិត្យឡើងវិញទៅលើចំណាត់ប្រភេទនៃឯកសារជាង ១២.០០០ ដែលជាប្រភេទឯកសារសម្ងាត់និងសម្ងាត់បំផុតមួយចំនួនទៀតក្នុងសំណុំរឿង ០០១។ ក្នុងនោះ អង្គជំនុំជម្រះបានធ្វើចំណាត់ប្រភេទឯកសារសរុបចំនួន ១.៧៤៩ ថាជាឯកសារសាធារណៈ។ ឯកសារទាំងនេះមានជាអាទិ៍ ឯកសារក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលរួមមាន "ចម្លើយសារភាព" និងជីវប្រវត្តិរបស់ជនរងគ្រោះ, ចម្លើយសាក្សី, ប្រតិចារឹកនៃសវនាការ *អសាធារណៈ (in camera)* និងដីកាចាត់ឲ្យស៊ើបសួរជំនួស។

ដំណើរការនៃការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនេះត្រូវបានអនុវត្តដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយនឹងការិយាល័យនិងអង្គភាពនានារបស់ អ.វ.ត.ក និងជាពិសេសដោយមានការរួមចំណែកពីអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង ការិយាល័យសហព្រះរាជអាជ្ញា អង្គភាពគាំពារជនរងគ្រោះ អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ និងផ្នែកគ្រប់គ្រងតុលាការ។ អង្គជំនុំជម្រះតុលាការកំពូលបានព្យាយាមរក្សាតុល្យភាពរវាងលក្ខខណ្ឌតម្លាភាពចេញពីគោលការណ៍ជាសារវន្តដែលគ្រប់គ្រងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក និងតម្រូវការក្នុងការរក្សាការសម្ងាត់ដើម្បីការពារភាពឯកជនរបស់ជនរងគ្រោះនិងសាក្សី និងតម្រូវការក្នុងការរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីដែលកំពុងអនុវត្ត។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា ការផ្សព្វផ្សាយឲ្យបានទូលំទូលាយនូវឯកសារទាក់ទងនឹងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការនេះ ស្របតាមអាណត្តិរបស់ អ.វ.ត.ក ដែលរួមចំណែកដល់ការផ្សះផ្សាជាតិ និងដើម្បីគាំទ្រដល់ដំណើរការនាពេលបច្ចុប្បន្នក្នុងការស្វែងរកការពិតក្នុងប្រវត្តិសាស្ត្រ។ អង្គជំនុំជម្រះសង្ឃឹមថា ការណ៍ដែលសាធារណជនទូទៅ អ្នកស្រាវជ្រាវ និងអ្នកសារព័ត៌មាន មានលទ្ធភាពច្រើនក្នុងការចូលទៅប្រើប្រាស់ឯកសារក្នុងសំណុំរឿង នឹងជួយលើកកម្ពស់ការពិភាក្សាជាសាធារណៈនិងដោយស្មោះត្រង់អំពីសោកនាដកម្មនៅប្រទេសកម្ពុជាក្នុងអតីតកាល ដោយផ្អែកទៅលើភ័ស្តុតាងច្បាស់លាស់ ដើម្បីជួយកាត់បន្ថយជាអតិបរិមាចំពោះការមិនទទួលស្គាល់ ការបំភ្លៃអង្គហេតុ និងការបង្ហាញការពិតតែមួយផ្នែកណានោះ។

ឯកសារចំនួន ៣ភាគ៤ ទៀតនៃឯកសារ ១២.០០០ នេះ ត្រូវបានចាត់ចំណាត់ថ្នាក់ក្នុងសំណុំឯកសារសំណុំរឿង០០២ សំណុំរឿង០០៣ និងសំណុំរឿង០០៤។ ដូច្នេះ ឯកសារទាំងនោះនឹងត្រូវពិនិត្យចាត់ចំណាត់ប្រភេទឡើងវិញនៅពេលដែលកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងឯកសារទាំងនោះបានចប់សព្វគ្រប់។ អង្គជំនុំជម្រះតុលាការកំពូលបានស្នើអង្គភាពបណ្ណសារឲ្យអនុវត្តសេចក្តីសម្រេចនេះ និងដាក់បញ្ជីឯកសារដែលត្រូវបានកំណត់ថាជាឯកសារសាធារណៈទៅក្នុងសំណុំរឿង។

សម្រាប់ព័ត៏មានលម្អិត សូមអាន “សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង” ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារលេខ F30/2។